# ការអប់រំ នៃ ពូជពង្សខ្មែរ

*ដោយ* **ឌី-ការ៉េត**

*(សិក្ខាសាលា អំពី"ខ្មែរមានពូជ" នៅវត្តពោធិវង្ស ប្រទេសបារាំង ថ្ងៃទី២៦ មេសា ២០០៩)*

***ខ្មែរមានពូជ*** គឺខ្មែរដែលកើតមក បានទទួលការអប់រំ ក្នុងគំនិតស្មារតី និងទំនៀមទម្លាប់ល្អ នៃប្រជាជនខ្មែរ។

ការស្រាវជ្រាវជាបន្ថែមថ្មីៗ ក្នុងប្រវត្តិសាស្រ្ត បានបង្ហាញថាប្រជាជនខ្មែរ (និងប្រជាជន"មន") មានពូជពង្សបន្តពីប្រជាជនមួយ ហៅថា"មុនឌុះ" (Munda) ដែលជាប្រជាជនរស់នៅប្រទេសឥណ្ឌា មុនគេបំផុត កាលពីជាង៣0.000ឆ្នាំមុនគ្រឹស្តសករាជ (គ.ស.)។ ដោយមិនព្រមទទួលរងអំណាច នៃពួកឈ្លានពានបរទេសជាបន្តបន្ទាប់ ចាប់ពីម្ភៃឆ្នាំ១0.000 មុនគ.ស. ប្រជាជនខ្មែរ បាននាំគ្នាចេញពីប្រទេសឥណ្ឌា បន្តិចម្តងៗ ហើយមកតាំងទីលំនៅ នៅលើទឹកដីខ្លួនថ្មីសព្វថ្ងៃ ពីម្ភៃឆ្នាំ៦.000 មុនគ.ស.។ ពួក“មម” (Mom) ហៅថា"មន" (Môn) ដែលជាប់ខ្សែស្រឡាយនិងខ្មែរ បានមកដល់ភូមា នៅម្ភៃឆ្នាំ៣.000 មុនគ.ស.។ ហេតុនេះ ជនជាតិខ្មែរបានមករស់នៅ លើទឹកដីសព្វថ្ងៃ មុនពួកសៀម ពួកឡាវ ពួកយួន ពួកចាម ចំនួនរាប់ពាន់ឆ្នាំ ដោយមានភាសា មានវប្បធ៌ម មានសាសនា មានចំណេះវិជ្ជា ផ្ទាល់ខ្លួន ហើយបានសាងសង់ប្រទេសខ្លួន ហៅថា “**ស្រុកខ្មែរ** ” យ៉ាងមាំមួនជាស្រេច។ លុះចាប់ពីដើមគ្រឹស្តសតវត្សទី១ ទើបខ្មែរមានការទាក់ទងជាថ្មី ជាមួយនិងពួកជនជាតិឥណ្ឌា ដែលមានឥទ្ធិពល មកនៅដល់ប្រទេសម៉ាឡេ នាពេលនោះ។

នៅក្នុងប្រវត្តិសាស្រ្តខ្មែរសព្វថ្ងៃ យើងបានដឹងខ្លះៗ តែអំពីសម័យហ្វ៊ូណន (នគរភ្នំ) សម័យចិនឡា សម័យអង្គរ ឬកម្ពុជា។ ប៉ុន្តែ នៅមុនសម័យហ្វ៊ូណន “**ស្រុកខ្មែរ**”ជារដ្ឋខ្លាំងពូកែមួយទៅហើយ ដែលគោរពលទ្ធិពិសេសមួយ ហៅថា“មត្តេយ្យកា” (មេម្តាយ ឬ ស្រី ជាធំ ជាអ្នកដឹកនាំ) និងកាន់សាសនាមួយ ដែលគោរពបូជា“មេ-បា” “នាងគង្ហីងព្រះធរណី និងព្រលឹង ក្រពើ” “អ្នកតា” ជាអាទិ។ ជនជាតិខ្មែរ បានគោរពបូជាគុណបារមីទាំងនេះ នៅគ្រប់សម័យទាំងអស់ ជាបន្តបន្ទាប់ រហូតមក ដល់សព្វថ្ងៃ។ នេះសឱ្យឃើញថា រហូតមកដល់សព្វថ្ងៃ ប្រជាជនខ្មែរ ជា“ពូជ”តែមួយ ជានិច្ច។

## ទេពកោសល្យ នៃប្រជាជនខ្មែរ

នៅក្នុងអតិតកាល គំនិតស្មារតីនិងចំណេះវិជ្ជា មិនមែន បានកើតឡើង ក្នុងរយៈតែ២0-៣0ឆ្នាំ ឬ១00ឆ្នាំទេ។ ប្រទេសឥណ្ឌា ឬចិន ដែលមានអារ្យធ៌មខ្ពស់ហើយ នៅពេលនោះ ក៏មិនដែលបានមកគ្រប់គ្រង ឬដឹកនាំប្រជាជនខ្មែរទេ។ តែប្រជាជននេះ មានទេពកោសល្យខ្ពស់ ដោយបានបង្កើត សំរាប់ជាតិសាសន៍ខ្លួនឯង នូវប្រព័ន្ធមួយដឹកនាំសង្គម និងប្រទេស (គឺរបប មត្តេយ្យកា) សាសនាមួយរបស់ខ្លួន (មេ-បា និងព្រះធម្មជាតិ) តួអក្សរនិងតួលេខមួយចំនួន (ដែលជា សញ្ញាផ្គុំគ្នា រវាងព្យញ្ជនៈនិងស្រៈដើម្បីបង្កើតជាពាក្យ - គឺមិនមែនជារូបភាពផ្គុំគ្នាទេ) និងបច្ចេកទេសធ្វើស្រែ-ចំការ ការនេសាទ ការងារលោហធាតុ (ដែក ស្ពាន់ ទង់ដែង មាស ប្រាក់...) ។ នៅដើមសម័យហ្វ៊ូណន (នគរភ្នំ) ពួកអ្នកដំណើរចិនបានឃើញថា “ខ្មែរជាជាងទង(ធ្វើគ្រឿងមាស-ប្រាក់) យ៉ាងប៉ិនប្រសប់ ជាជាងត្បាញសំពត់យ៉ាងល្អ ប្រណីត ជាអ្នកចេះកែខៃទឹកដីយ៉ាងចំណាន ដើម្បី កសិកម្ម ចេះធ្វើសំពៅដើរសមុទ្រ មានប្រវែងជាង៣0ម៉ែត្រ... ”។

នៅសម័យហ្វ៊ូណន (នគរភ្នំ) ចិនឡា និងអង្គរ បច្ចេកកសិកម្ម សំណង់ ចម្លាក់ និងសិល្បៈផ្សេងៗ បានចំរើនជាខ្លាំងទៀត ដោយខ្មែរបានស្រង់យក គំនិតស្មារតីនិងចំណេះវិជ្ជា អំពីឥណ្ឌា ប៉ុន្តែដោយរក្សាចរិតដើម នៃជាតិ សាសន៍ខ្លួន ជានិច្ច។ ខ្មែរពូកែខាងវិទ្យាសាស្រ្ត ជាពិសេសគណិត វិទ្យារូបវិទ្យា តារាវិទ្យា និងសំណង់។ ខ្មែរបានបង្កើតរបៀបរាប់លេខនព្វន្តដែលមានមូលដ្ឋានប្រាំ (១, ២, ៣, ៤, ៥,) ហើយបំបែកដល់លេខដប់។ ក្នុងវិស័យអក្សរសាស្រ្ត និង សិល្បសាស្រ្ត ខ្មែរបានបង្កើតកំណាព្យនិងចំរៀង ជាច្រើនបែបបទ ហើយតន្រ្តីនិងរបាំខ្មែរ មានឈ្មោះល្បីល្បាយឆ្លងប្រទេស ឆ្លងជាតិសាសន៍ ឆ្លងសតវត្ស មកដល់សព្វថ្ងៃ។ រីឯវិជ្ជាធ្វើម្ហូបខ្មែរ ក៏ជាស្នាដៃយ៉ាងធំមួយទៀត ដែលត្រូវបានជនជាតិឯទៀត រៀនធ្វើតាម រហូតមកដែរ។

# ប្រពៃណី នៃការអប់រំខ្មែរ

ទេពកោសល្យទាំងនេះ បានកើតមាន ដោយសារជនជាតិខ្មែរចូលចិត្តរៀនសូត្រវិជ្ជា ហើយមានស្មារតីផ្ចិតផ្ចង់ការងារណាស់។ នៅសម័យហ្វូណន់ (នគរភ្នំ) ក្នុងគ.ស.ទី៣ យើងបានដឹងថា មានឯកសារជាច្រើនណាស់ ស្ដីអំពីវិជ្ជានិងការងារផ្សេងៗ ដែលគេរក្សាទុកក្នុងបណ្ណាល័យនានា។ នៅក្នុងលទ្ធិ ព្រាហ្មណ៏សាសនា គេរៀនសូត្រជាច្រើនបំផុត អំពីគម្ពីរ"វេទ" (les Vedas) ជាភាសាសំស្ក្រឹត ដែលនៅក្នុងនោះ មានវិជ្ជាសព្វយ៉ាង ជាអាទិគឺ សាសនា អក្សរសាស្ត្រ វេយ្យាករណ៏ ច្បាប់(នៃអាទិទេព) វេជ្ជ-សាស្ត្រ គណិតសាស្ត្រ តារាសាស្ត្រ ស្ថាបនកម្ម សេដ្ឋសាស្ត្រ កសិកម្ម នយោបាយ សង្គ្រាមសាស្ត្រ និងសិល្បសាស្ត្រ ឬបច្ចេក-ទេសផ្សេងៗទៀត។ ការចេះដឹងរបស់អ្នកប្រាជ្ញខ្មែរ នាសម័យនោះ បានលេចឮទៅទីឆ្ងាយៗណាស់។ នៅសតវត្សទី៣ ប្រទេសចិនបាននិមន្តមហាភិក្ខុខ្មែរ ខាងពុទ្ធសាសនា ជាច្រើនអង្គ ឱ្យទៅបង្ហាត់បង្រៀនព្រះពុទ្ធធ៏ម នៅប្រទេសគេ។ ក្រោយមកទៀត ចិនបាននាំយកអ្នកតន្ត្រីខ្មែរ ឱ្យទៅសំដែងនិងបង្ហាត់បង្រៀន ពួកអ្នកតន្ត្រីគេដែរ។ នៅក្រុងអង្គរ មានពួកអ្នកប្រាជ្ញ ពីឥណ្ឌានិងជ្វា មកសិក្សានៅសាកលវិទ្យាល័យខ្មែរ ជាបន្តបន្ទាប់។ នៅសម័យនោះ ស្រីខ្មែរក៏មានចំណេះវិជ្ជាខ្ពង់ខ្ពស់ មិនចាញ់ប្រុសទេ។

នៅសម័យក្រោយៗមកទៀត ខ្មែរក៏តែងតែអប់រំកូនចៅខ្លួន ក្នុងគោលការណ៏ធំៗពីរ ជានិច្ច គឺកូនស្រី-ប្រុស ៖

១- ត្រូវយល់ថា ចំណេះវិជ្ជា ជាប្រភពនៃទ្រព្យសម្បត្តិ និងឫទ្ធានុភាព ហេតុនេះគេត្រូវខឹតខំស្វែងរកចំណេះវិជ្ជា ជានិច្ចកាល។

២- ត្រូវកាន់ខ្ជាប់ខ្ជួន នូវវិន័យសិលធ៏ម និងវិន័យកិរិយា-មារយាទ ក្នុងជិវភាពផ្ទាល់ខ្លួន និងជាមួយអ្នកផង ក្នុងសង្គម។ (នេះគឺដើម្បីរក្សា"ឯកភាព"នៃសង្គម ដោយខ្មែរបានគិតថា មនុស្សម្នាក់ៗត្រូវដឹងអំពី"ទីកន្លែង"របស់ខ្លួន នៅក្នុងសង្គម - គឺ គ្រួសារ ភូមិស្រុក ឬ សហគមន៏ជាតិ - បើពុំដូច្នោះទេ អ្នកនោះឯងជា"*មនុស្សជ្រួជាតិ*"។ ប៉ុន្តែ"ទីកន្លែង"នោះ អាចផ្លាស់ប្ដូរ ដោយសារគុណសម្បត្តិ ឬគុណវិបត្តិ ជាបន្ទាប់មក របស់មនុស្សនោះដែរ)។

## . វិន័យផ្ទាល់ខ្លួន និងវិន័យក្នុងសង្គម

លទ្ធិមត្តេយ្យកាខ្មែរ នៅមានអានុភាពជាខ្លាំង នៅសម័យហ្វូណន់(នគរភ្នំ) រហូតដល់សម័យអង្គរធំ នៃព្រះបាទជ័យវរម្ម័ន ទី៧។ នៅសម័យទាំងនោះ ដែលបានដណ្ដើមអំណាច ដោយកម្លាំងឃោរឃៅ តែងតែយកមហេសី ឬបុត្រីស្ដេចដែលចាញ់ខ្លួននោះ ធ្វើជាមហេសីខ្លួន ដើម្បីឱ្យរាជ្យខ្លួន មានលក្ខណៈត្រឹមត្រូវ ស្របច្បាប់ប្រពៃណី។ដោយសារអានុភាពនេះ ខ្មែរទូទៅ តែងប្រាថ្នា ចង់បានកូនស្រី ជាងកូនប្រុស ព្រោះកូនស្រីជាអ្នកទទួលមរតកទ្រព្យ-សម្បត្តិ ហើយនឹងនៅថែរក្សាម្ដាយ-ឪពុកជានិច្ច។ នៅគ្រប់សម័យ ប្រជាជនខ្មែរគោរពសិទ្ធិសេរីភាពរបស់ស្រី ដូចគ្នានិងប្រុស យ៉ាងហោចណាស់ចំពោះភ្នែកសង្គម។ ចំណុចទាំងនេះ ខុសអំពីទស្សនៈ របស់ឥណ្ឌាឬចិន។ ម្យ៉ាងទៀត សង្គមខ្មែរ ជាមហាគ្រួសារតែមួយ ដែលសមាជិកហៅរកគ្នា ថាជា បង ប្អូន ពូ មីង យាយ តា... ដូចនៅក្នុងគ្រួសារផ្ទាល់ របស់ខ្លួន។

តាំងពីកំណើត រហូតដល់អាយុ៧ឬ៨ឆ្នាំ កូនខ្មែររស់ក្នុងសេរីភាព នៅក្នុងជុំរុំគ្រួសារផង និងក្នុងបរិវេណនៃអ្នកជិតខាង នៅក្នុងភូមិស្រុកជាមួយផង។ ម្ដាយ-ឪពុក បងៗ និងអ្នកជិតខាង តែងជួយបង្ហាត់បង្រៀនកុមារតូចៗ ឱ្យលេងល្បែង ឱ្យចេះហែលទឹក ឱ្យរៀនធ្វើកិច្ចការបន្តិចបន្តួច។ ចាប់ពីអាយុ៧ឬ៨ឆ្នាំ កូនប្រុសៗត្រូវទៅរៀនអក្សរ លេខនព្វន្ត ការងារជាង និង ធ៏មអាទិ នៅសាលា (អាស្រម វត្ត)។ យុវជន ដែលមានប្រាជ្ញាឈ្លាសវៃ អាចនឹងបន្តការសិក្សា ជាមួយនិងគ្រូ-អាចារ្យនៅទីក្រុងទៀត។

ប៉ុន្តែ ជនជាតិខ្មែរតែងយកចិត្តទុកដាក់ជាបឋម ក្នុងការអប់រំសិលធ៏ម និងកិរិយា-មារយាទ របស់កូនស្រី-ប្រុស។ ការអប់រំនេះ មានទ្រង់ទ្រាយពីរយ៉ាង គឺមានការរៀបចំពិធីផ្សេងៗផង និងការបង្រៀនក្បួន"ច្បាប់" សាស្ត្រា គម្ពីរផ្សេងៗ ឱ្យចេះចាំស្ទាត់ផង។

ពិធីអប់រំ តាមទំនៀមទម្លាប់ មានរៀបចំជាហូរហែ ក្នុងឱកាសអាពាហ៏ពិពាហ៏ខ្មែរ ដូចជាពិធីសូមការអនុញ្ញាតអំពីមេ-បា ពិធីគោរពក្រុមគ្រួសារទាំងសង្ខាង ពិធីកាត់សក់ ពិធីខាត់ធ្មេញ ពិធីបង្វិលពពិល ពិធីបង្ហាញគូស្រករថ្មី ដល់សហគមន៏ភូមិស្រុក

។ល។ ពិធីអាពាហ៍ពិពាហ៍ខ្មែរ ជាការផ្សំផ្គុំមនុស្សពីរនាក់ ជាគូនិងគ្នាហើយ តែក៏ជាពិធីបង្រួបបង្រួមគ្រួសារពីរ ព្រមទាំងក្រុម-ញាតិទាំង៧សន្តានសង្ខាង និងអ្នកភូមិស្រុកទាំងពីរផង។ ពាក្យថា"មេ-បា" មិនមានន័យត្រឹមតែម្ដាយ-ឪពុក ជីដូន-ជីតា ទេ។ "មេ"គឺធាតុឬព្រលឹងដែលផ្ដល់ជីវិត ឬឧបត្ថមជីវិត។ "បា" គឺធាតុឬព្រលឹងដែលការពារជីវិត។ "អ្នកតា"ជាព្រលឹងនៃវិរបុរសដែលការពារភូមិស្រុក។

ការអប់រំមួយផ្នែកទៀត គឺការបង្រៀន"ច្បាប់"ទូន្មានខ្លួន ជាច្រើនចំពូក។ កម្រង"ច្បាប់"ទាំងនោះ ពិតជាមរតកសិលធ៌ម និងជាសម្បត្តិសតិបញ្ញាមួយ របស់ប្រជាជនខ្មែរ ដែលគេបាន តាក់តែងនិង
បង្រៀនគ្នីគ្នា ពីស្រុករមួយទៅស្រុករមួយទៀត ជាច្រើន រយឆ្នាំមកហើយ (ប្រហែលពីសម័យលង្វែកមក ឬពីមុននោះផង)។ គេបានតែង"ច្បាប់"ទាំងអស់នោះ ជាបទកំណាព្យផ្សេងៗ ដើម្បីឱ្យអ្នកស្ដាប់ចាប់ចិត្ត និងចងចាំសេចក្ដីដោយងាយ។ "ច្បាប់"ដែលគេស្គាល់ច្រើន គឺ *ច្បាប់ប្រុស ច្បាប់ស្រី ច្បាប់កូនចៅ ច្បាប់កេរ្តិ៍កាល ច្បាប់ក្រម ច្បាប់ត្រីនេតិ ច្បាប់ពាក្យចាស់ ច្បាប់ទូន្មានខ្លួន ច្បាប់វិធូរបណ្ឌិត ច្បាប់រាជនេតិ (ឬច្បាប់ព្រះរាជសម្ភារ)* ។ "ច្បាប់"ទាំងនោះ ជាកម្រងវិន័យ សំរាប់កសាង គំនិតស្មារតីនៃបុគ្គលម្នាក់ៗហើយ ប៉ុន្តែសំខាន់បំផុត គឺវិន័យដែល បុគ្គលម្នាក់ៗនោះត្រូវកាន់ ក្នុងកិរិយា-មារយាទខ្លួន ចំពោះអ្នកនៅជុំវិញខ្លួន មានម្ដាយ-ឪពុក បង-ប្អូន គ្រូអាចារ្យ ប្ដីឬប្រពន្ធ មនុស្សចាស់ទុំ ឬអ្នកមានអំណាចដឹកនាំ។

ក្នុងវិន័យផ្ទាល់ខ្លួន កូនខ្មែរត្រូវជាអ្នកឧស្សាហ៍ធ្វើការងារ ឧស្សាហ៍រកភោគផល សំរាប់សេចក្ដីត្រូវការរបស់ខ្លួននិងគ្រួសារ ចេះគិតគូរថែរក្សាផ្ទះសម្បែង និងទ្រព្យសម្បត្តិខ្លួន កុំលួចប្លន់គេ កុំសុំទានគេ... ៖
- *កុំខ្ជិលកុំច្រអូស ទៅងងូសរត់សុំគេ គេមិនឱ្យឯងទេ តែគឺមោះព្រោះខ្ជិលដាំ ។*
- *ទោះធ្វើស្រែចំការ ឱ្យឧស្សាហ៍មើលថែទាំ កុំខ្ជិលកុំប្រចាំ ចបចូកជីកស្មៅវល្លិផង ។*
- *កុំទុកដៃទទេ ជាងទំនេរ បោចស្មៅព្រៅ ខាងផ្ទះខាងលំនៅ ឱ្យវាលកាលកើតសុខា* ។ (ច្បាប់ប្រុស)

ជាមួយគ្នានេះ គេត្រូវជៀសវាង អំពីអំពើ"ឆ្កួត"បី គឺការសប្បាយនិងភេទ និងគ្រឿងស្រវឹង និងល្បែងភ្នាល់គ្នា ៖
- *លោកថាឆ្កួតបី ឆ្កួតមួយនិងស្រី ឆ្កួតមួយនិងស្រា ឆ្កួតមួយនិងល្បែង អំពើពាលា ឆ្កួតនេះហៅមហា ឆ្កួតក្រៃកន្លង។* (ច្បាប់កូនចៅ)

នៅក្នុងសង្គម កូនខ្មែរត្រូវដឹងថា"*សម្ដី សជាតិ មារយាទ សត្រកូល*" ឬថា"*សម្ដីជាឯក លេខជាទោ អក្សរជាត្រី*") គឺគេត្រូវមានឥរិយាបថទន់ភ្លន់(ដូចភុជង្គ) មានភាពរាបសា មានការគោរព ហើយសំខាន់បំផុត គេត្រូវនិយាយស្ដីដោយភាសាសមគួរ ពិរោះ មិនប្រើពាក្យព្រហើន ឬពាក្យ"បាតផ្សារ " ៖
- *រៀនបទរៀនបាទចាស កុំច្រឡាសលើរៀមច្បង ស្រដីនិងអ្នកផង ពាក្យឱ្យគួរកុំឯងអ្ហី ។*
- *អឺអើអញដាច់សាច់ ឆ្គងពាក្យពេចន៍គេស្រដី ដើមដៀលឱ្យអប្រិយ ស្រដីថាកូនអត់ពូជ ។* (ច្បាប់ប្រុស)

ការគោរព និងការដឹងគុណ ចំពោះម្ដាយ-ឪពុក និង គ្រូអាចារ្យ ត្រូវមានកិរ៏តខ្ពស់ បំផុត ៖
- *ព្រះជនកព្រះជននី បើនឹងស្រដី ប្រសើរពេកពន់ ថាភ្នំព្រះសុមេរុ៍ នោះហោងមហាធ្ងន់ បើថានិងគណន៍ ពុំអាចកន្លង ។* (ច្បាប់ក្រម)
- *កុំធ្វើវាយមាយ និងគ្រូបាធ្យាយ ទុកស្មើអម្ចាស់ សង្វាតសរសេរ សូត្ររៀនឱ្យណាស់ ប្រាជ្ញាយល់ច្បាស់ នាំញាតិទាំងឡាយ ។*
- *វិគ្រូបាធ្យាយ អាចឱ្យពណ្ណរាយ មានរូបរស្មី ហើយឱ្យរុងរឿង អស់បញ្ចិន្ទ្រិយ ស្មើព្រះជននី ជនកសោតហោង ។* (ច្បាប់ក្រម)

អ្នកចេះដឹង អ្នកមានទ្រព្យធន ត្រូវជួយឃឹតយោងអ្នកខ្សោ ជួយឧបត្ថមអ្នកក្រីក្រ។ សាមគ្គីភាពនេះ ជាករណីកិច្ចសិលធ៌មនៃកូនខ្មែររាល់រូប ដែលត្រូវពឹងពាក់គ្នា ទៅវិញទៅមក ជានិច្ច ៖
- *អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន ។*

- *អ្នកខ្ពស់រក្សាទាប ដោយសភាពធម៌បូរាណ អ្នកឆ្មែតរក្សាឃ្លួន នាអ្នរុងរក្សាឆ្មារ ។*
- *រក្សាទៅមករឹង ឥតកំដឹងអស់អម្បាល ចំណេរចេរកាន់កាល ដូចរបងស្រោស់បន្ល ។* (ច្បាប់ពាក្យចាស់)
- *ហែអស់កូនចៅ តំណក្រោយទៅ ត្រកូលវង្សា ចូលចេះរាប់រក ស្រករត្តីគ្នា ខុសគាប់កាចជា អត់ឱនត្រងរង ។* (ច្បាប់កូនចៅ)

ជាមួយគ្នានេះ មនុស្សម្នាក់ៗត្រូវដឹងច្បាស់ នូវការទទួលខុសត្រូវរបស់ខ្លួន ត្រូវចេះទទួលស្គាល់ការភ័ន្តច្រឡំ ឬកំហុសរបស់ខ្លួន ហើយចេះចែករំលែកទុក្ខនិងសុខ ជាមួយញាតិមិត្តខ្លួនផង ៖

- *ពាក្យចាស់ពីព្រេង ទោសខ្លួនឯងមើលពុំយល់ ទោសគេតូចសោតសល់ រមិលយល់ប៉ុនទាំងភ្នំ ។*
- *ចូលព្រៃសត្វសាហាវ រកអំពាវគ្នាមកជុំ ដល់បានស្ករទឹកឃ្មុំ ពួនក្នុងផ្ទះស៊ីម្នាក់ឯង ។*
- *បានហើយចង់បានទៀត ឆ្លៀតហើយឆ្លៀតពុំគិតឈ្វេង មើលយល់តែមុខឯង មិនយល់គេឯទៀតផង ។* (ច្បាប់ពាក្យចាស់)

ប៉ុន្តែ គេត្រូវមានការប្រយ័ត្ន ក្នុងការសេពគប់ជាមួយអ្នកឯទៀត ជានិច្ចដែរ ៖

- *កុំកាចកុំស្លូតពេក កុំចំអេករៀនរហ័ស កុំខ្លាចកុំហ៊ានណាស់ ឱ្យរំពឹងរំពៃគ្រប់ ។ (ច្បាប់ប្រុស)*
- *កុំទុកចិត្តបរទេស កុំទុកចិត្តអភិនេស្រ្តម៏ កុំទុកចិត្តអភិប្រាយ ប្រើស្ទុំលែងខ្ពស់ រំពឹងឱ្យឆ្ងាយ ស្តាប់ពាក្យបរិយាយ បណ្តិបមេជី ។* (ច្បាប់ព្រះរាជសម្ភារ)
- *អ្នកមួយថៃចូវ រអែរអូវ វៀចវេបូស្សា បញ្ចើចបញ្ចើ ពាក្យពើមាយា ដូចកលផ្លែល្វា ល្អល្អះតែក្រៅ ។...*

## . វិន័យនយោបាយ

នៅក្នុងជំនឿលើ"មេ-បា" ប្រជាជនខ្មែរយល់ថា វាសនារបស់ខ្លួនពឹងពាក់ទាំងស្រុង លើអ្នកដឹកនាំស្រុក គឺមហាក្សត្រ និងនាម៉ឺនមុខមន្ត្រី។ ហេតុនេះ ឧត្តមគតិខ្មែរ ក្នុងលទ្ធិនយោបាយផ្សេងៗ (មត្តេយ្យកា ព្រហ្មញ្ញសាសនា ពុទ្ធសាសនា) មហាក្សត្រនិងមន្ត្រីរដ្ឋ មានកាតព្វកិច្ចបឋមបំផុត គឺផ្តល់និងការពារសេចក្តីចំរើន ក្នុងជីវភាព ឱ្យប្រជាជន(“រាស្ត្រទាស ”)។ ឧទាហរណ៍ជាក់ស្តែង ពីសម័យអង្គរ គឺមហាក្សត្រខ្មែរខឹតខំណាស់ រកវិធីទប់និងចែករំលែកទឹក សំរាប់រាស្ត្រធ្វើស្រែចំការ (មានការសាងបារាយ ប្រកបដោយបច្ចេកខ្ពស់ ជាអាទិ) ខំធ្វើផ្លូវគមនាគមន៏គោកនិងទឹក សំរាប់រាស្ត្រធ្វើដំណើររកស៊ី ខំសាង សង់មន្ទីព្យាបាលរោគ សំរាប់ថែទាំសុខភាពរាស្ត្រ ខំសាងសង់ សាលារៀន សំរាប់បណ្តុះបណ្តាលចំណេះវិជ្ជា របស់រាស្ត្រ ។ល។ ក្នុងគ្រប់លទ្ធិមហាក្សត្រត្រូវគ្រប់គ្រង រដ្ឋនិងប្រជាជន តាមបទបញ្ជាច្បាប់ (ព្រះធ៏ម ឬ“រដ្ឋធម្មនុញ្ញ”) មិនមែនតាមអំពើចិត្តខ្លួនទេ។ នៅសម័យនគរភ្នំ និងអង្គរ ពួកព្រាហ្មណ៏បុរោហិត ជាអ្នកត្រួតពិនិត្យកិច្ចការមហាក្សត្រ ឬដឹកនាំរដ្ឋបាលជាន់ខ្ពស់ផ្ទាល់តែម្តង ដើម្បីឱ្យសមស្រប និងគាលការណ៏ធ៏ម-ច្បាប់ របស់ប្រទេស។

ជាបឋម មហាក្សត្រខ្លួនឯង ត្រូវមានចំណេះវិជ្ជាគ្រប់វិស័យ និងមានសិលធ៏ម យ៉ាងប្រាកដប្រជានិងជ្រៅជ្រះណាស់ ពិព្រោះ“*ព្រះអង្គ ដែលជាអម្ចាស់លើផែនដី ត្រូវបានជាព្រះគ្រូ នៃមនុស្សលោកទាំងអស់*”។ សិលាចារិកនៅអង្គរ បានលើកជាអាទិថា ព្រះបាទយសោវរហ្ម័ន ទី១, ព្រះបាទជ័យវរហ្ម័ន ទី៥, ព្រះបាទសុរិយាវរហ្ម័ន ទី១, ព្រះបាទឧទ័យទិត្យាវរហ្ម័ន ទី២ ឬព្រះបាទជ័យវរហ្ម័ន ទី៧ សុទ្ធជាមហាក្សត្រ មានចំណេះវិជ្ជាជ្រៅជ្រះណាស់ អំពីអក្សរសាស្ត្រ វេយ្យាករណ៏ ទស្សនះវិជ្ជា ច្បាប់ វិទ្យាសាស្ត្រ... និងសិល្បសាស្ត្រ ឬបច្ចេកទេសផ្សេងៗទៀត។ មហាក្សត្រទាំងនេះ ក៏មានព្រះហឫទ័យសប្បុរសណាស់ និងមានការអាណឹតអាសូរយ៉ាងធំធេង ចំពោះជនក្រទុគ្គត ៖“*គឺដូចជាឪពុកសម្លាញ់ របស់កូនទាំងអស់គ្នា ព្រះអង្គ (ព្រះបាទជ័យវរហ្ម័ន ទី៥) តែងតែជូតទឹកភ្នែកនៃប្រជារាស្ត្រ ដោយហត្ថាដ៏វែងរបស់ព្រះអង្គ*”។ គុណសម្បត្តិសំខាន់បំផុតទី៣ នៃមហាក្សត្រខ្មែរ គឺសេចក្តីក្លហានដ៏មោះមុត ក្នុងកិច្ចការពារអត្ថប្រយោជន៏ របស់ប្រជារាស្ត្រ និងប្រទេសជាតិ។ នៅក្នុងរាជ្យព្រះបាទសុរិយាវរហ្ម័ន ទី១ “*ទោះជាមនុស្សដេកលក់ នៅក្នុងព្រៃម្នាក់ឯង ក៏មិនមានការព្រួយបារម្ភ ក្រែងចោរមកលួចទ្រព្យសម្បត្តិរបស់ខ្លួនដែរ*”។

នៅក្នុងលទ្ធិពុទ្ធសាសនា នៃសម័យក្រោយអង្គរ ព្រះសង្ឃពុទ្ធសាសនា មិនត្រួតពិនិត្យកិច្ចការមហាក្សត្រ និងមិនដឹកនាំរដ្ឋបាលជាតិផ្សេងៗទេ ហើយគ្រាន់តែធ្វើកិច្ចទូន្មាន ឱ្យមហាក្សត្រពិចារណា តាមគោលការណ៍នៃ“*ទសពិធរាជធម៌*”។ ច្បាប់ត្រីនេតិ បានកំណត់ល្អិតល្អន់ អំពីគុណសម្បត្តិចាំបាច់ នៃមហាក្សត្រ និងនាម៉ឺនមុខមន្ត្រី ៖

- *បពិត្រមហារាជ ទ្រើសទ្រង់អំណាច អញ្ជើញស្ដេចស្ដាប់ ទំនឹមទំនង នេះហោងជាច្បាប់ ទុកជាសណ្ដាប់ នៃនរជនជាតិ ។*
- *នរអ្នកណា នឹងចូលទៅជា វររាជអមាត្យ សេនាមន្ត្រី កវីជាអាទិ រៀនច្បាប់ជាខ្នាត តែងទុករៀងទៅ ។* (ច្បាប់ត្រីនេតិ)

នៅទីបំផុត ក្នុងករណី ដែលមហាក្សត្រមិនគោរព ចំពោះច្បាប់រដ្ឋ និងករណីកិច្ចចាំបាច់ ខាងលើនេះ អ្នកប្រាជ្ញខ្មែរយល់ថា ការរិះគន់និងការបះបោរនៃប្រជាជន ជាការត្រឹមត្រូវ ៖

- *ជាក្សត្រយ៍ពុំរៀនធម៌ ពុំដោះសាជម្ងឺទ្រូង រាស្ត្រទាសនឹងចំកោង អាក់ចិត្តខឹងសត្វចោមរោម ។*
- *នឹងកើតក្ដៅក្រហាយ ទុក្ខអន្តរាយកពផ្ទៃក្រោម រាស្ត្រផងនឹងខឹងចោម ជ្រោមខ្ចាត់ខ្ចាយទទៃណា ។* (ច្បាប់វិធូរបណ្ឌិត)

## សេចក្ដីបញ្ចប់ ៖ “ខ្មែរអ្នកជា”

កូនខ្មែរគ្រប់សម័យ តែងតែប្រកាន់ប្រពៃណី របស់ជាតិខ្លួនណាស់ ទោះបីមានការប្រែប្រួល ក្នុងស្រុកខ្លួនម្ដេចក្ដី ពិព្រោះគេមានជំនឿយ៉ាងជ្រៅ លើផលល្អនៃប្រពៃណីនោះ។ ប្រជាជនខ្មែរមានជំនឿថា ធម៌-ច្បាប់ ប្រពៃណី និងការចេះដឹង ជាកិច្ចធានាឱ្យមានសន្តិភាពសង្គម និងជាកត្តាសំខាន់ៗបំផុត បង្កបង្កើតសេចក្ដីចំរើន និងឥទ្ធិពលខ្មែរ។ ម្យ៉ាងទៀត លំដាប់សក្តិក្នុងសង្គមខ្មែរ ឈរលើកេរ្តិ៍នៃការពិសោធន៍ របស់បុគ្គលម្នាក់ៗ គឺលើអាយុ លើកំពស់សិលធ៌ម ឬលើសមត្ថភាពជាវិជ្ជមាន របស់បុគ្គលម្នាក់ៗ។ ហេតុនេះ នៅក្នុងវិស័យនយោបាយ ខ្មែរតែងយល់ថា គេត្រូវប្រគល់អំណាច ទៅឱ្យបុគ្គលដែលចេះដឹងច្បាស់អំពីធ៌ម-ច្បាប់ ហើយប្រតិបត្តិធ៌ម-ច្បាប់ គឺថាជា"**ព្រះបាទធម្មិក**"។

ប្រពៃណីខ្មែរមិនកើតមក ពីទ្រឹស្ដីសាសនាណាមួយ ទាំងស្រុងទេ។ គឺជាគោលការណ៍ ដែលកើតមកពីការពិសោធន៍ ក្នុងជីវភាពជាក់ស្ដែង ចំនួនរាប់ពាន់ឬរាប់ម៉ឺនឆ្នាំ របស់ប្រជាជនខ្មែរ។ ការពិសោធន៍ធំបំផុត របស់ប្រជាជនខ្មែរ គឺសង្គ្រាមរាប់ពាន់ឆ្នាំ ដែលបានកើតឡើង ពីក្រៅស្រុកមកផង និងនៅក្នុងស្រុកខ្លួនផង ។ ជាច្រើនពាន់ឆ្នាំមកហើយ ទ្វីបអាស៊ីជាទ្វីបដែលស្គាល់អំពើឃោរឃៅ និងសង្គ្រាម ឥតបានស្រាកស្រាន្តយូរទេ តាំងពីប្រទេសឥណ្ឌា ដល់ប្រទេសចិន និងតាមកោះធំៗ នៃសមុទ្រជិតខាង ។ ហេតុនេះ ជាច្រើនពាន់ឆ្នាំមកហើយ ស្រុកខ្មែរ មិនមែនរស់ជា"កោះសន្តិភាព"ទេ ហើយការស្វែងរក*ឯកភាពជាតិ* ដើម្បីបំបាត់សង្គ្រាមផ្ទៃក្នុង និងផ្ដុំកម្លាំងជាតិ ជំនះសត្រូវពីក្រៅ ជាគោលដៅទីមួយ នៃការអប់រំជាប្រពៃណី របស់ប្រជាជនខ្មែរ ។ គេយល់ទៀតថា ឯកភាពជាតិ នឹងកើតមានបាន លុះត្រាតែកូនខ្មែរ ចេះការគោរពគ្នា ដើម្បីស្រឡាញ់គ្នាបាន, ចេះស្រឡាញ់គ្នា ទើបចង់ជួយថែរក្សាគ្នា ជួយបណ្ដុះបណ្ដាលគ្នា (នេះគឺ សាមគ្គីភាព), ចេះសាមគ្គីគ្នា ទើបតទល់និងសត្រូវបរទេស ដល់មានជោគជ័យបាន ។

ប្រពៃណីនៃការប្រយុទ្ធតស៊ូ នៃប្រជាជនខ្មែរ គឺ ការជំរុញកូនខ្មែរ មានទស្សនៈវែងឆ្ងាយ និងឱ្យមានមហិច្ឆិតាធំធេង សំរាប់ជាតិនិងមាតុប្រទេស របស់ខ្លួន។ ខ្មែរមានពូជ ដែល ជាពួកអ្នកមានភាពថ្លៃថ្នូរ សុទ្ធសឹងជាអ្នកប្រកាន់សេរីភាពខ្លួនណាស់ គឺថាគេជា“**ខ្មែរអ្នកជា**” ហើយគេមិនអាចដាក់ខ្លួន ជា មនុស្សខ្ញុំគេឡើយ។

**ឌី-ការ៉េត**